ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ......៣៤៦......អពដ

GENERAL DEPARTMENT OF TAXATION

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០១៤

# សេចក្តីជូនដំណឹង
# អំពីកម្រិតការប្រាក់ទីផ្សារសម្រាប់ប្រាក់ខ្ចី ឆ្នាំ២០១៣

អនុលោមតាមបទប្បញ្ញត្តិនៃមាត្រា១៨ នៃច្បាប់ស្តីពីសារពើពន្ធ ផ្នែកទី២.៥ និងផ្នែកទី៥.៩ នៃប្រកាសស្តីពីពន្ធលើប្រាក់ចំណេញលេខ១០៥៩ ប្រក.សហវ.ពដ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៣ និងយោងតាមសេចក្តីណែនាំអំពីការកំណត់ចំណាយការប្រាក់របស់សហគ្រាស លេខ១៥១ អពដ. ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ អគ្គនាយកដ្ឋានពន្ធដារបានកំណត់អត្រាការប្រាក់ទីផ្សារសម្រាប់ប្រាក់ខ្ចីឆ្នាំ២០១៣ ចំនួន១២% ក្នុងមួយឆ្នាំ។ អត្រាការប្រាក់នេះបានមកពីការគណនាមធ្យមភាគនៃអត្រាការប្រាក់ឲ្យខ្ចីរបស់ធនាគារពាណិជ្ជធំៗក្នុងស្រុកចំនួន ៨ (ប្រាំបី)។

អាស្រ័យហេតុនេះគ្រប់អង្គភាពពន្ធដារ និងគ្រប់សហគ្រាសជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះ ចំពោះលទ្ធផលសារពើពន្ធសម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៣ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ

អគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល

**ចម្លងជូន** :
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  “ដើម្បីជូនជ្រាប”
- គ្រប់អង្គភាពពន្ធដារ
  “ដើម្បីអនុវត្ត”
- ឯកសារ-កាលប្បវត្តិ